Co-funded by the European Union
សហការឧបត្ថម្ភដោយ សហភាពអឺរ៉ុប



# ការផ្តល់វ៉ាក់សាំងការពារជំងឺកូនមាន់

**សមាគមបណ្តាញកសិករ និងធម្មជាតិ**
ផ្ទះលេខ ១៣ ផ្លូវលេខ ១០០៧ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កម្ពុជា
www.fnn-kh.org

# គម្រោងបង្កើនការងារជនបទដើម្បីស្តារសេដ្ឋកិច្ច ដែលរងផលប៉ះពាល់ដោយសារជម្ងឺកូវីដ១៩
## Rural Enployment for COVID-19 Economic Recovery (RECOVER) Project

គម្រោងនេះ រួមចំណែកស្តារសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន នៅក្នុងតំបន់ជុំវិញបឹងទន្លេសាបដោយធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពស្បៀង ប្រាក់ចំណូល និងឱកាសការងារសម្រាប់សហគមន៍កសិកម្ម និងនេសាទ ក៏ដូចជាសម្រាប់ពលករចំណាកស្រុកដែលវិលត្រឡប់មកប្រទេសវិញ ដោយប្រើប្រាស់បណ្តាញទំនាក់ទំនងដែលមានស្រាប់រវាងក្រុមហ៊ុនឯកជន អង្គការដៃគូ សង្គមស៊ីវិលក្នុងស្រុក និងដៃគូផ្សេងទៀត ដើម្បីពង្រឹងខ្សែច្រវ៉ាក់ផលិតកម្មមាន់ ដោយធ្វើការផ្សារភ្ជាប់ក្រុមផលិត ក្រុមកែច្នៃ និងអតិថិជន។

កសិករ និងប្រជានេសាទខ្នាតតូច ក្នុងតំបន់គោលដៅនៃ គម្រោងអាចបង្កើនផលិតភាព និងការប្រើប្រាស់ស្បៀងនៅក្នុងផ្នែកសាកវប្បកម្ម និងផលិតកម្មចិញ្ចឹមមាន់ តាមរយៈការអនុវត្តបច្ចេកទេសកសិកម្ម ផលិតកម្ម និងសេវាកម្មដែលមានប្រសិទ្ធភាព។

ពលករចំណាកស្រុកដែលវិលត្រឡប់ មកវិញ និងនិយោជិតដែលបានបាត់បង់ការងារនៅក្នុងវិស័យដែលរងផលប៉ះពាល់ដោយសារកូវីដ ១៩អាចទទួលបានជំនាញទាក់ទងនិង់ទីផ្សារ ហិរញ្ញប្បទានសមរម្យ និងសេវាគាំពារសង្គម។

ទោះជាក្រុមផលិត មានការអនុវត្តតាមបច្ចេកទេសយ៉ាងណាក៏ដោយ ក៏នៅទទួលបានប្រាក់ចំណូលទាប។ ពោលគឺក្រុមផលិតនៅមិនទាន់យល់អំពីបច្ចេកទេសការពារជំងឺមាន់ ដែលជាផ្នែកមួយសំខាន់នៃខ្សែច្រវ៉ាក់ផលិតកម្មមាន់ កត្តានេះ ធ្វើឲ្យក្រុមផលិតមាន់មានការបាត់បង់ផលប្រយោជន៍ និងដើមទុនទាំងស្រុងតែម្តង។

ដូចនេះ គម្រោងបានរៀបចំឯកសារនេះឡើង ដើម្បីណែនាំបច្ចេកទេសខ្លះៗ អំពីការផ្តល់វ៉ាក់សាំងការពារជំងឺកូនមាន់ សម្រាប់ក្រុមផលិតកម្មមាន់ នៃសហគមន៍កសិកម្ម។

## សេចក្តីផ្តើម

កសិករ ភាគច្រើនចិញ្ចឹមមាន់តែងតែទទួលបរាជ័យ បញ្ហាចំបងនៃការបរាជ័យនោះ គឺមាន់ឈឺ និងងាប់អស់ៗតែម្តង ដែលធ្វើឲ្យគាត់ខាតបង់ទុនច្រើនមិនតែប៉ុណ្ណោះ អ្នកខ្លះឈប់ចញ្ចឹមមាន់តែម្តង។ កាលណាមាន់មិនឈឺ និងមិនងាប់ គឺជាកត្តាជោគជ័យរបស់កសិករ។ ជាទូទៅ ដើម្បី ចៀសកុំឲ្យមាន់ឈឺ និងស្សាំនឹងជំងឺ កសិករត្រូវធ្វើវ៉ាក់សាំងមាន់ឲ្យបានគ្រប់ប្រភេទជំងឺមាន់ និងទាន់ពេលវេលា ទៅតាមអាយុកាលមាន់។

តើកត្តាអ្វីខ្លះដែលធ្វើអោយការចាក់វ៉ាក់សាំងមានប្រសិទ្ធិភាព?

- មុនធ្វើវ៉ាក់សាំង យើងត្រូវ៖
  - ក្រុងមាន់ដែលមានសុខភាពល្អទុកដោយឡែកពីមាន់មានសុខភាពមិនល្អ
  - ធ្វើអ្វីមួយសំគាល់លើមាន់ដែលត្រូវធ្វើវ៉ាក់សាំងលើកទី1
  - មានធុងទឹកកក+ទឹកកកសំរាប់ដាក់វ៉ាក់សាំង សម្ភារ: និងឧបករណ៍ ...
  - ទិញវ៉ាក់សាំងដែលមានសុពលភាព ដបវ៉ាក់សាំងនៅមានទ្រង់ទ្រាយល្អ។

- ពេលធ្វើវ៉ាក់សាំង យើងត្រូវ៖
  - វ៉ាក់សាំងត្រូវបានរក្សាទុកដាក់បានល្អ (ត្រជាក់)
  - ធ្វើវ៉ាក់សាំងមាន់ពេលត្រជាក់ (ព្រឹក ឬល្ងាច មិនអោយប៉ះពន្លឺព្រះអាទិត្យ)
  - ធ្វើវ៉ាក់សាំងតែលើមាន់មានសុខភាពល្អប៉ុណ្ណោះ
  - យកក្រណាត់ត្រជាក់រុំដបវ៉ាក់សាំងទើបចាប់កាន់/ ឬយកដៃជ្រលក់នឹងទឹកកកសិន
  - វ៉ាក់សាំងត្រូវធ្វើទៅតាមប្រភេទ (ចាក់ដឹងចាក់ បន្តក់ដឹងបន្តក់ ជូសស្លាបដឹងជូសស្លាប)
  - ឧបករណ៍ស្អាត និងមានអនាម័យ
  - មាន់១ក្បាលធ្វើវ៉ាក់សាំងតែ១ដងក្នុង១ពេលប៉ុណ្ណោះ (ចាក់2ដងអាចស្លាប់មាន់)។

- ក្រោយពេលធ្វើវ៉ាក់សាំង៖
  - ដាក់ទឹកអោយមាន់ផឹកអោយបានគ្រប់គ្រាន់ និងផ្តល់ចំណីគ្រប់គ្រាន់
  - ក្រុងមាន់ដែលធ្វើវ៉ាក់សាំងរួច ១-៣ថ្ងៃ
  - បាចកំបោរកន្លែងធ្វើវ៉ាក់សាំង និងពីក្រោមទ្រុងដែលរក្សាទុកមាន់ទើបធ្វើវ៉ាក់សាំង
  - កាកសំណល់វ៉ាក់សាំងត្រូវដុតចោល ល្អជាងកប់ចោល
  - ធ្វើកំណត់ត្រាថ្ងៃដែលបានធ្វើវ៉ាក់សាំង និងថ្ងៃដែលត្រូវធ្វើរំលឹកវ៉ាក់សាំងលើកទី២ និងទី៣
  - តាមដានសុខភាពមាន់ (បំបែកមាន់ឈឺចេញបើមាន)។

យើងត្រូវធ្វើវ៉ាក់សាំងការពារជំងឺមាន់ ៣ ប្រភេទ គឺ៖

១. វ៉ាក់សាំងការពារជម្ងឺ ញ៉ីវកាស (ជម្ងឺដង្កោកាច់)។ ជម្ងឺនេះ ច្រើនផ្ទុះឡើងនៅចន្លោះខែកុម្ភៈ ដល់ចុងខែឧសភា (រដូវប្រាំង)

២. វ៉ាក់សាំងការពារជម្ងឺ អុត (ដុះដុំពកនៅលើក្បាល ឬនៅកន្លែងដែលគ្មានរោម)។ វាអាចកើតមានគ្រប់ពេលវេលា

៣. វ៉ាក់សាំងការពារជម្ងឺអាសន្នរោគ។ ជំងឺអាសន្នរោគច្រើនផ្ទុះនៅខែមិថុនា ដល់ខែធ្នូ (រដូវវស្សា)។

# ១. ការផ្តល់វ៉ាក់សាំងការពារជំងឺញូវកាស (ជំងឺដង្កាកាច់)

យើងត្រូវផ្តល់វ៉ាក់សាំងញូវកាស ២ដង លើកទី១៖ ពេលកូនមាន់មានអាយុ ៣ ទៅ ៧ថ្ងៃ និងលើកទី២៖ ពេលកូនមាន់អាយុ ២១ ទៅ ៣០ ថ្ងៃ។ ការពារជំងឺបាន ៣ខែ។

ប្រភេទវ៉ាក់សាំង៖ វ៉ាក់សាំងមាន ២ ប្រភេទ គឺ៖

- អាយធូ
- ញូវកាសអឹម (មិនអាចប្រើប្រាស់ជាមួយកូនមាន់បានទេ)



**សម្ភារៈ៖**

- សឺរ៉ាំងចំណុះ ៥ មីលីលីត្រ ឬ៥ សេសេ ម្ជុល
- វ៉ាក់សាំងញូវកាស (សូមអាន ការណែនាំលើសំបកថ្នាំ) និងទឹកលាយ
- កូនដបជ័រសម្រាប់ដាក់វ៉ាក់សាំងបន្តក់
- ធុងទឹកកក និងទឹកកកសម្រាប់ក្លាសេវ៉ាក់សាំង



សឺរ៉ាំង



វ៉ាក់សាំង



ទឹកលាយវ៉ាក់សាំង



កូនដបជ័រ



ធុងទឹកកក

ចំណាំ៖

សម្ភារៈ និងវ៉ាក់សាំងទាំងអស់នេះ អាចរកទិញបាននៅកន្លែងលក់ចំណីសត្វ ឬ ពេទ្យសត្វ។

## វិធីប្រើប្រាស់វ៉ាក់សាំង៖

- សូមអានការណែនាំពីវិធីប្រើ ឧទាហរណ៍៖ វ៉ាក់សាំងមាន លេខ ២៥ ទៅ៥០ មានន័យថា ប្រើសម្រាប់ កូនមាន់ពី ២៥ ទៅ ៥០ក្បាល។
- កូនមាន់អាយុ ៥ថ្ងៃ ត្រូវបន្តក់វ៉ាក់សាំងអាយធូ   កូនអាយុ ១ខែ ត្រូវចាក់វ៉ាក់សាំងញីវកាសអឹម
- វ៉ាក់សាំងត្រូវរក្សានៅកន្លែងត្រជាក់ជានិច្ច (ពី ២ ទៅ ៨ អង្សាសេ)។ ចៀសវាងត្រូវកំដៅថ្ងៃ។

- លាយវ៉ាក់សាំង នឹងទឹកលាយ ៥សេសេ




- ចាប់ទ្រកូនមាន់ផ្ងាជើងឡើងលើដោយដាក់ជើងទៅខាងចុងម្រាមដៃយើង



- យកល្បាយវ៉ាក់សាំងនេះ ដាក់ចូលក្នុងកូនដបប្លាស្ទិច រួចយកមកបន្តក់ចូលក្នុងភ្នែក ឬ ច្រមុះ ឬមាត់ ចំនួន ២ដំណក់ក្នុងកូនមាន់ ១ក្បាល។



- បន្តក់បែបនេះរហូតអស់កូនមាន់។

## ២. វ៉ាក់សាំងការពារជំងឺអុតមាន់

យើងចាក់វ៉ាក់សាំងការពារជំងឺអុត តែ១ដង ក្នុង១វដ្តនៃជីវិតមាន់ គឺធ្វើក្រោយពីចាក់វ៉ាក់សាំងញូវកាសបាន ៥ថ្ងៃ ពោលគឺនៅពេលកូនមាន់អាយុ ចន្លោះពី ៧ថ្ងៃ ដល់ ១២ថ្ងៃ។ ការពារជំងឺបាន ១ វដ្តនៃជីវិតមាន់។

**សម្ភារ:**

- សឺរ៉ាំងចំណុះ ៥ មីលីលីត្រ ឬ៥ សេសេ ម្ជុលលេខធំ សម្រាប់បូមទឹកលាយ និងម្ជុលមុខ២មានរន្ធ ដូចម្ជុលម៉ាស៊ីនដេរ សម្រាប់ចាក់។





- វ៉ាក់សាំងអុត និងទឹកលាយ





- ធុងទឹកកក និងទឹកកកសម្រាប់ក្លាសេវ៉ាក់សាំង



**វិធីប្រើប្រាស់វ៉ាក់សាំង៖**

- សូមអានការណែនាំពីវិធីប្រើ ឧទាហរណ៍៖ វ៉ាក់សាំងមាន លេខ ១០០ មានន័យថា ប្រើសម្រាប់ កូនមាន់ពី ១០០កូនមាន់
- កូនមាន់អាយុ១០ថ្ងៃ ត្រូវបន្តក់វ៉ាក់សាំង
- វ៉ាក់សាំងត្រូវរក្សានៅកន្លែងត្រជាក់ជានិច្ច (ពី ២ ទៅ ៨ អង្សាសេ)។ ចៀសវាងត្រូវកំដៅថ្ងៃ។

- បូបទឹកលាយ ពសេសេ ចាក់បញ្ចូលក្នុងដបវ៉ាក់សាំង រួចក្រឡុកឲ្យល្បាយថ្នាំស្មើសាច់



- ចាប់ទ្រកូនមាន់ផ្ងាជើងឡើងលើ ដោយដាក់ជើងទៅខាងចុងម្រាមដៃយើង



- បើកគម្របដបវ៉ាក់សាំងចេញ ជ្រលក់ម្ជុលមុខ២ចូលក្នុងដបថ្នាំ រួចយកមកចាក់ទំលុះលើស្បែកស្តើងនៃស្លាបកូនមាន់







- ចាក់បែបនេះរហូតអស់កូនមាន់។

## ៣. វ៉ាក់សាំងការពារជំងឺអាសន្នរោគ

ជំងឺអាសន្នរោគច្រើនផ្ទុះនៅខែមិថុនា ដល់ខែធ្នូ (រដូវវស្សា)។ យើងចាក់វ៉ាក់សាំងការពារជំងឺអាសន្នរោគតែ១ដង ការពារជំងឺបានរយៈពេល ៦ខែ។

**សម្ភារះ**

- សឺរ៉ាំងចំណុះ ៥ មីលីលីត្រ ឬ៥ សេសេ ម្ជុលលេខធំសម្រាប់បូមថ្នាំ និងម្ជុលតូចខ្លីសម្រាប់ចាក់មាន់
- វ៉ាក់សាំងអាសន្នរោគ ១ដបចំណុះ១០០មីលីលីត្រ សម្រាប់កូនមាន់១០០ក្បាល
- ធុងទឹកកក និងទឹកកកសម្រាប់ក្លាសេវ៉ាក់សាំង។






**វិធីប្រើប្រាស់វ៉ាក់សាំង៖**

- ប្រើសម្រាប់កូនមាន់អាយុពី១០ ទៅ ១២ សប្តាហ៍
- វ៉ាក់សាំងត្រូវរក្សានៅកន្លែងត្រជាក់ជានិច្ច (ពី ២ ទៅ ៨ អង្សាសេ)។ ចៀសវាងត្រូវកំដៅថ្ងៃ។
- បូមវ៉ាក់សាំងដោយប្រើសារ៉ាំងម្ជុលធំ រួចដូរដាក់ម្ជុលតូចខ្លីពេលចាក់កូនមាន់



- ចាប់ទ្រកូនមាន់ផ្ងាជើងឡើងលើ ដោយដាក់ជើងទៅខាងចុងម្រាមដៃយើង



- ចាក់លើសាច់ដុំទ្រូង ឬគល់ស្លាបចំនួន១មីលីលីត្រ ឬ១សេសេ



- ចាក់បែបនេះរហូតអស់កូនមាន់។

ចំណាំ៖

- ពេលទិញវ៉ាក់សាំងត្រូវពិនិត្យមើលគុណភាពឲ្យបានច្បាស់លាស់ (ដបវ៉ាក់សាំងនៅមានទ្រង់ទ្រាយល្អ) ពិសេសថ្ងៃផុតកំណត់ប្រើប្រាស់។

- វ៉ាក់សាំង និងសម្ភារៈបម្រើការងារធ្វើវ៉ាក់សាំងអាចរកទិញបាននៅកន្លែងលក់ចំណីសត្វ ឬនៅកន្លែងពេទ្យសត្វ។

- ពេលចាក់វ៉ាក់សាំងកូនមាន់រួចរាល់ ហើយនៅសល់វ៉ាក់សាំង សូមយកវ៉ាក់សាំងដែលនៅសល់នោះ ទៅកប់ ឬដុតចោល ដើម្បីចៀសវាងជំងឺស្ទុះនឹងវ៉ាក់សាំង។

# កម្មវិធីវ៉ាក់សាំងកូនមាន់

| ប្រភេទវ៉ាក់សាំង | អាយុកូនមាន់ | វិធីប្រើ | កម្រិត | ការពារជំងឺបាន |
|---|---|---|---|---|
| ជំងឺញូវកាស | លើកទី១៖ ៣ - ៧ថ្ងៃ (អាយធូ)<br>លើកទី២៖ ២១ - ៣០ថ្ងៃ (ញូវកាសអឹម) | បន្តក់២ដំណក់ លើភ្នែក ឬច្រមុះ ឬ តាមមាត់ | ២ដង | ៣ខែ |
| ជំងឺអុត | ១០ថ្ងៃ | ជួសបន្ទះស្តើងនៃស្លាប | ១ដង | ១វដ្តជីវិត |
| ជំងឺអាសន្នរោគ | ១០ - ១២ សប្តាហ៍ | ចាក់សាច់ដុំទ្រូង ឬគល់ស្លាប | ១ មីលីលីត្រ<br>ឬ ១សេសេ | ៦ ខែ |

ឯកសារនេះរៀបចំឡើងក្រោមជំនួយថវិកាពីសហភាពអឺរ៉ុប។ ខ្លឹមសារនៅក្នុងឯកសារនេះគឺជាការទទួលខុសត្រូវរបស់ សមាគមបណ្តាញកសិករនិងធម្មជាតិ (FNN) និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។

This video was produced with the financial support of the European Union. Its contents are the sole responsibility of Farmer and Nature Net Association (FNN) and do not necessarily reflect the views of the European.

(+855) 95 984 843 / 86 728 245
pansopheap1@gmail.com
www.fnn-kh.org